# ទ្រឹស្តីស្តីពីអង្គហេតុចំបងដែលជាធាតុផ្សំ

## បណ្តឹងទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ

ថ្ងៃទី18 ខែមិថុនា ឆ្នាំ2014

ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវកិច្ចការច្បាប់ទូទៅ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្ត្រាចារ្យ Tsuji Yasuhiko




2
ការទាមទារ (សិទ្ធិ)
សាលក្រមច្រានចោលនូវការទាមទារ
ការអះអាង (អង្គហេតុ)
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
A
B
C
សារភាព
មិនទទួលស្គាល់
សារភាព
ចំណុចវិវាទ → បរាជ័យក្នុងការបញ្ជាក់ភស្តុតាង
ការបញ្ជាក់ភស្តុតាង (ភស្តុតាង)
ការទទួលស្គាល់អង្គហេតុ
បញ្ជាក់ភស្តុតាង
បញ្ជាក់ភស្តុតាងតប
ដើមចោទ
ចុងចម្លើយ


ការតវ៉ា
3
ការទាមទារ (សិទ្ធិ)
សាលក្រមទទួលស្គាល់នូវការទាមទារ
ការអះអាង (អង្គហេតុ)
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
A
B
C
សារភាព
សារភាព
សារភាព
អង្គហេតុតវ៉ា
D
មិនទទួលស្គាល់
D
ចំណុចវិវាទ → មានជោគជ័យក្នុងការបញ្ជាក់ភស្តុតាង
ការបញ្ជាក់ភស្តុតាង (ភស្តុតាង)
ការទទួលស្គាល់អង្គហេតុ
បញ្ជាក់ភស្តុតាងតប
បញ្ជាក់ភស្តុតាង
ដើមចោទ
ចុងចម្លើយ




5

លោកមេធាវី ខ្ញុំចង់ពិគ្រោះជាមួយលោក។
នៅថ្ងៃទី4 ខែមេសា ឆ្នាំ2011 ខ្ញុំបានទិញដីពី A ក្នុងតម្លៃ១លានដុល្លារ។
ខ្ញុំបានគិតថា នឹងប្រើដីនោះនាអនាគត តែឥឡូវនេះ មានទាន់សាងសង់អ្វី
នៅឡើយទេ។

លោក X





6

ថ្ងៃមុន ពេលដែលខ្ញុំជិះកាត់ដីនោះ ក៏ឆ្លៀតចូលមើលស្ថានភាព ហើយក៏ឃើញ ដីទំនេររបស់ខ្ញុំនោះ មានគេដាក់គ្រឿងសំណង់នៅលើនោះ។
ខ្ញុំក៏បានស្រាវជ្រាវទៅឃើញថា Y បានប្រើសម្រាប់ដាក់សម្ភារះរបស់គាត់។

សូមជួយទាមទារយកដីរបស់ខ្ញុំពី Y មកឱ្យខ្ញុំវិញផង។







7




【តើអ្វីទៅ អង្គហេតុដែលជាមូលហេតុនៃការទាមទារ?】

ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា 155

កម្មសិទ្ធិករអាចទាមទារឱ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនវិញបាន ។ ប៉ុន្តែ បញ្ញត្តិ នេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកកាន់កាប់នោះមានមូលហេតុគតិយុត្ត នៃសិទ្ធិកាន់កាប់ ចំពោះកម្មសិទ្ធិករ ។




③ចុងចម្លើយគ្មានសិទ្ធិកាន់កាប់ទេ។ តើនេះអាចគឺជាអង្គហេតុដែលជាមូលហេតុនៃការទាមទារដែរឬទេ ?

មានន័យថា ស្តីពីអង្គហេតុ "ចុងចម្លើយគ្មានសិទ្ធិកាន់កាប់" តើដើមចោទត្រូវធ្វើការអះអាងនិងបញ្ជាក់ភស្តុតាង ឬយ៉ាងណាដែរ ?
ឬក៏ ស្តីពីអង្គហេតុ "ចុងចម្លើយមានសិទ្ធិកាន់កាប់" តើចុងចម្លើយត្រូវធ្វើការអះអាងនិងបញ្ជាក់ភស្តុតាង ឬយ៉ាងណាដែរ ?




ជាទូទៅ ស្តីពីអង្គហេតុណាមួយដែលមានអត្ថិភាព មានការងាយស្រួលនឹងបញ្ជាក់ភស្តុតាង។

(ឧទាហរណ៍) អង្គហេតុនៃកិច្ចសន្យា អាចបញ្ជាក់ដោយលិខិតនៃកិច្ចសន្យាបាន។
អង្គហេតុនៃការសង អាចបញ្ជាក់ដោយវិក័យប័ត្របាន។

ផ្ទុយទៅវិញ ការបញ្ជាក់ថា អង្គហេតុណាមួយគ្មានអត្ថិភាពទេ គឺពិបាកណាស់។
គេតែងតែហៅថាជា "ការបញ្ជាក់ព្រាយបីសាច"។

(ឧទាហរណ៍) ការបញ្ជាក់ថា មិនបានធ្វើកិច្ចសន្យា
ការបញ្ជាក់ថា មិនបានទទួលនូវសំណង




ស្តីពីសិទ្ធិកាន់កាប់របស់ចុងចម្លើយក៏ដូចគ្នាដែរ។

បើសិនជាចុងចម្លើយអះអាងអំពីភតិសន្យា ចុងចម្លើយមានការងាយស្រួលនឹងបញ្ជាក់នូវអត្ថិភាពនៃភតិសន្យានេះ តាមរយៈលិខិតនៃភតិសន្យា។
ផ្ទុយទៅវិញ បើសិនជាឱ្យដើមចោទធ្វើការបញ្ជាក់ថា ចុងចម្លើយពុំបានបង្កើតភតិសន្យាទេ គឺជាការពិបាកណាស់។ នេះគឺជាការបញ្ជាក់ព្រាយបីសាច។

⇩

ការតម្រូវឱ្យចុងចម្លើយធ្វើការបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិកាន់កាប់ គឺមានសមធម៌។




បើសិនជាយើងមើលពីទម្រង់នៃមាត្រាក៏ឃើញដូចគ្នាដែរ គឺ សិទ្ធិកាន់កាប់របស់ចុងចម្លើយ គឺជាអង្គហេតុតវ៉ា។

【ក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា 155】
កម្មសិទ្ធិករអាចទាមទារឱ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនវិញបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកកាន់កាប់នោះមានមូលហេតុគតិយុត្ត នៃសិទ្ធិកាន់កាប់ ចំពោះកម្មសិទ្ធិករ ។




ម្ល៉ោះហើយ សិទ្ធិកាន់កាប់របស់ចុងចម្លើយ គឺជាអង្គហេតុតវ៉ា។




①សូមពិចារណាអំពីបញ្ហា "ដើមចោទមានកម្មសិទ្ធិលើដី"។

តាមពិត អង្គហេតុដែលជាមូលហេតុនៃការទាមទារ ត្រូវតែជា "អង្គហេតុ" ។
(ឧ.) ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ។
បានទទួលប្រាក់។

ក៏ប៉ុន្តែ តើដើមចោទXមានកម្មសិទ្ធិដីឬទេ គឺជាបញ្ហាវាយតម្លៃតាមផ្លូវច្បាប់ទេ មិនមែនជាអង្គហេតុទេ។

ចំណុចនេះ តើអាចទទួលបានឬទេ ?


ការទាមទារ
(សិទ្ធិ)
ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
14
ការអះអាង
(អង្គហេតុ)
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
?
①ដើមចោទមានកម្មសិទ្ធិលើដី
②ចុងចម្លើយកាន់កាប់ដី
ដើម្បីអាចធ្វើការវាយតម្លៃតាមផ្លូវច្បាប់ថា ដើមចោទXមានកម្មសិទ្ធិលើដី តើត្រូវមានអង្គហេតុអ្វីខ្លះ ?


ការទាមទារ
(សិទ្ធិ)
ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
15
ការអះអាង
(អង្គហេតុ)
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
?
①ដើមចោទមានកម្មសិទ្ធិលើដី
②ចុងចម្លើយកាន់កាប់ដី
ដី
អង្គហេតុដែលជាមូលហេតុនៃលទ្ធកម្ម①
A
អង្គហេតុដែលជាមូលហេតុនៃលទ្ធកម្ម②
B
③
C
④
D
⑤
E
⑥
F
⑦
G
⑧
H
⑨
I
⑩
J
⑪
K
⑫
L
⑬
កម្មសិទ្ធិ




ក៏ប៉ុន្តែ ការឱ្យដើមចោទធ្វើការអះអាងអំពីអង្គហេតុដែលជាមូលហេតុនៃលទ្ធកម្មទាំងអស់ គឺជាការមិនសមស្របតាមស្ថានភាពជាក់ស្តែងទេ។

កម្មសិទ្ធ គឺជាទស្សនៈមួយដែលមនុស្សធម្មតាក៏យល់ដឹងដែរ ហេតុនេះហើយ អាចចាត់ទុកដូចជាអង្គហេតុមួយ ក៏មិនបញ្ហាដែរ។




ដើមចោទ អាចអះអាងអំពី ①ដើមចោទមានកម្មសិទ្ធិលើដី ជាអង្គហេតុដែលជាមូលហេតុនៃការទាមទារបាន មិនបញ្ហាទេ។




【សេចក្តីសន្និដ្ឋាន】

អង្គហេតុដែលជាមូលហេតុនៃការទាមទារ ក្នុងបណ្តឹងទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ

①ដើមចោទមានកម្មសិទ្ធិលើដី

②ចុងចម្លើយកាន់កាប់ដី

18




ក្រោមសភាពការណ៍បែបនេះ គេបានដាក់ពាក្យបណ្ដឹង ដោយមានX ជាដើមចោទ។
បន្ទាប់ពីនេះ សូមមើលអំពីគំនិតនៃការរៀបចំចំណុចវិវាទទៅតាមប្រភេទនៃវិវាទរបស់ចុងចម្លើយ Y ។

ប្រភេទ① ការតវ៉ាអំពីសិទ្ធិកាន់កាប់
ប្រភេទ② ការតវ៉ាអំពីការបាត់បង់កម្មសិទ្ធិ
ប្រភេទ③ ការមិនទទួលស្គាល់នូវលទ្ធកម្មកម្មសិទ្ធិ

19

ប្រភេទទី① ការតវ៉ាអំពីសិទ្ធិកាន់កាប់


20
X
Y
នៅថ្ងៃទី15 ខែមីនា ឆ្នាំ2014 រវាងខ្ញុំនិង X បានបង្កើតភតិសន្យាស្តីពីដី ដោយកំណត់ថ្លៃឈ្នួល 200ដុល្លារក្នុងមួយខែ ហើយអំឡុងពេលជួលគឺ 10ឆ្នាំ។
បន្ទាប់មក នៅថ្ងៃដដែលនោះ Xបានប្រគល់ដីនោះមកឱ្យខ្ញុំ។
ដូច្នេះ ខ្ញុំមានសិទ្ធិកាន់កាប់ដីនោះត្រឹមត្រូវ។
(ឥឡូវនេះគឺថ្ងៃទី18 ខែមិថុនា ឆ្នាំ2014)


21
X
Y
រវាងខ្ញុំនិង Y ធ្លាប់បានចរចារអំពីការជួលដីដែរ។
ក៏ប៉ុន្តែ ស្តីពីថ្លៃឈ្នួល ចរចារមិនត្រូវរ៉ូវគ្នាទេ។ ដូច្នេះ មិនទាន់បានបង្កើតភតិសន្យាទេ។
ខ្ញុំមិនដែលបានប្រគល់ដីនោះទៅឱ្យ Y ទេ។
Yបានចាប់ផ្តើមកាន់កាប់តាមទំនើងចិត្តរបស់គាត់។




23

បញ្ហាដែល Xមានកម្មសិទ្ធិលើដីនោះ គឺមិនមែនជាអង្គហេតុទេ គឺជាការវាយតម្លៃតាមផ្លូវច្បាប់។

ការទទួលស្គាល់នូវការវាយតម្លៃតាមផ្លូវច្បាប់បែបនេះ គេហៅថា ការ**សារភាពអំពីសិទ្ធិ**។

តើការសារភាពអំពីសិទ្ធិនេះ អាចចាត់ចែងដូចគ្នានឹងការសារភាពធម្មតាដែរឬទេ ?



24

ការសារភាព គឺជាការទទួលស្គាល់នូវអង្គហេតុដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ខ្លួន។

ឧទាហរណ៍ ស្តីពីរឿងក្តីទាមទារឱ្យសងប្រាក់កម្ចី ក្នុងករណីដែលចុងចម្លើយបានទទួលស្គាល់ថា ខ្លួនបានខ្ចីប្រាក់ពីដើមចោទ ហើយបានអះអាងអំពីការតវ៉ានៃការសង ពេលនោះ ការទទួលស្គាល់ថា គាត់បានខ្ចីប្រាក់ពីដើមចោទ គឺជាការសារភាព។

25

អានុភាពនៃការសារភាព

- ភាគីមិនចាំបាច់ធ្វើការបញ្ជាក់ភស្តុតាងអំពីអង្គហេតុនោះទេ។ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា123 កថាខ័ណ្ឌទី2)
- តុលាការមិនអាចទទួលស្គាល់ផ្ទុយនឹងការសារភាពនោះបានទេ (គ្មានបញ្ញត្តិណាមួយចែងច្បាស់លាស់ទេ តែនេះគឺជាអានុភាពដែលបានមកពីគោលគំនិតគោរពឆន្ទៈរបស់ភាគី។)
- ការដកការសារភាព ត្រូវបានកម្រិតតឹងរ៉ឹង។ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា123 កថាខ័ណ្ឌទី3)



26

ការសារភាពធម្មតា និង ការសារភាពអំពីសិទ្ធិ  តើខុសគ្នាយ៉ាងណាដែរ ?

ការសារភាពធម្មតា គឺជាការទទួលស្គាល់នូវអង្គហេតុ
(ឧ.) បានបង្កើតកិច្ចសន្យាខ្ចីបរិភោគជាប្រាក់។
បានទទួលប្រាក់។

តើមានអង្គហេតុនោះឬគ្មាន? ភាគីអាចវិនិច្ឆ័យដោយខ្លួនឯងបាន។
ការទទួលខុសត្រូវដោយខ្លួនឯង។

⇩

អាចទទួលស្គាល់នូវអានុភាពខ្លាំង  ក៏មិនជាបញ្ហាដែរ។

- អង្គហេតុដែលបានសារភាព មិនចាំបាច់ធ្វើការពិនិត្យភស្តុតាងទេ។
- តុលាការមិនអាចធ្វើការទទួលស្គាល់អង្គហេតុផ្ទុយពីការសារភាពបានទេ។
- ភាគីមិនអាចដកការសារភាពបានធូរៗទេ។

27

ការសារភាពធម្មតា និង ការសារភាពអំពីសិទ្ធិ  តើខុសគ្នាយ៉ាងណាដែរ ?

ការសារភាពអំពីសិទ្ធិ គឺជាការសារភាពដែលមានភ្ជាប់នូវការវាយតម្លៃតាមផ្លូវច្បាប់។
(ឧ.) ខ្ញុំមានកំហុស។
អ្នកឯងមានកម្មសិទ្ធិ។

ការវាយតម្លៃតាមផ្លូវច្បាប់ គឺតុលាការជាអ្នកធ្វើ។
មិនអាចប្រគល់ឱ្យភាគីធ្វើការវិនិច្ឆ័យបានទេ។

⇩

មិនអាចទទួលស្គាល់នូវអានុភាពនៃការសារភាពបានទេ។

28

(ឧ.) ឧទាហរណ៍ស្តីពីការសារភាពអំពីសិទ្ធិ     គ្រោះថ្នាក់ចរាចរ




មានកំហុស ឬគ្មាន  គឺជាការវាយតម្លៃតាមផ្លូវច្បាប់  ដូច្នេះ នេះគឺជាការសារភាពអំពីសិទ្ធិ។

អានុភាពនៃការសារភាពមិនកើតឡើងទេ។

- ស្តីពីការមាន ឬគ្មានកំហុសរបស់Y មិនចាំបាច់ធ្វើការពិនិត្យភស្តុតាងទេ
- តុលាការអាចវិនិច្ឆ័យថា Yគ្មានកំហុសក៏បានដែរ។
- Yអាចដកការសារភាពវិញបាន។

29

ក៏ប៉ុន្តែ ទោះជាមានការសារភាពអំពីសិទ្ធិក៏ដោយ  ក៏មានករណីខ្លះដែល
អាចទទួលស្គាល់នូវអានុភាពនៃការសារភាពនោះបាន។

①ករណីដែលមានខ្លឹមសារដែលអាចទទួលស្គាល់នូវអង្គហេតុជាក់ស្តែង

②ករណីដែលអ្នកធម្មតាក៏អាចវិនិច្ឆ័យអំពីបញ្ហានោះបាន

30

ករណីលើកលែង① ករណីដែលមានខ្លឹមសារដែលអាចទទួលស្គាល់នូវអង្គហេតុជាក់ស្តែង

(ឧទាហរណ៍)




ខ្ញុំបើករថយន្តបណ្តើរ ចុចទូរស័ព្ទបណ្តើរ មិនបានមើលទៅមុខទេ។
ម្យ៉ាងទៀត ខ្ញុំបានបើកក្នុងល្បឿន120kmក្នុង១ម៉ោង។
ហេតុនេះហើយ នេះគឺជាកំហុសរបស់ខ្ញុំ។




អង្គហេតុជាក់ស្តែង ដូចជាការមិនបានមើលទៅមុខ ការបើកក្នុងល្បឿន120kmក្នុង១ម៉ោង គឺជាការសារភាព។

31

ករណីលើកលែង② ករណីនៃបញ្ហាដែលអ្នកជម្ងតាក៏អាចវិនិច្ឆ័យបាន

(ឧទាហរណ៍)

បញ្ហាមានកម្មសិទ្ធិ ឬគ្មាន គឺជាការវាយតម្លៃតាមផ្លូវច្បាប់ ដូច្នេះការទទួលស្គាល់បញ្ហានេះ គឺជាការសារភាពអំពីសិទ្ធិ។
ក៏ប៉ុន្តែ កម្មសិទ្ធិ គឺជាទស្សនៈមួយដែលអ្នកជម្ងតាក៏មានការយល់ដឹងច្រើន ហើយអាចវិនិច្ឆ័យបានងាយស្រួល។
ម្ល៉ោះហើយ បញ្ហាមានកម្មសិទ្ធិ ឬគ្មាន អាចគិតដូចគ្នានឹងអង្គហេតុបាន។




គឺជាការសារភាព ហើយអានុភាពនឹងកើតមានឡើង។

## សរុប

32

| | ការសារភាពធម្មតា | ការសារភាពអំពីសិទ្ធិ |
|---|---|---|
| កម្មវត្ថុ | អង្គហេតុ | ការវាយតម្លៃតាមផ្លូវច្បាប់ |
| ឧទាហរណ៍ជាក់ស្តែង | បានទទួលប្រាក់<br><br>បានសន្យាសង | ខ្ញុំមានកំហុស |
| អានុភាព | • មិនចាំបាច់ពិនិត្យភស្តុតាង។<br>• តុលាការមិនអាចធ្វើការទទួលស្គាល់អង្គហេតុផ្ទុយនឹងការសារភាពបានទេ។<br>• ភាគីមិនអាចដកការសារភាពបានងាយស្រួលទេ។ | មិនមានអានុភាពសារភាពទេ |
| ករណីលើកលែង | | ① ករណីដែលមានខ្លឹមសារដែលអាចទទួលស្គាល់នូវអង្គហេតុជាក់ស្តែង<br>② ករណីនៃបញ្ហាដែលអ្នកធម្មតាក៏អាចវិនិច្ឆ័យបាន |









ក្រមរដ្ឋប្បវេណី មាត្រា597 (ការបង្កើតភតិសន្យា)

ភតិសន្យា ត្រូវមានអានុភាព ដោយភាគីម្ខាង សន្យាថាឱ្យភាគីម្ខាងទៀតប្រើប្រាស់ និង អាស្រ័យផល ពីវត្ថុណាមួយ ចំណែកឯភាគីម្ខាងទៀត សន្យាថាបង់ថ្លៃឈ្នួលចំពោះវត្ថុនោះ ។

## ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ

36

ការទាមទារ (សិទ្ធិ)

ការអះអាង (អង្គហេតុ)




ឧទាហរណ៍ រវាងXនិងY ទោះជាមានការបង្កើតភតិសន្យាក៏ដោយ តែបើសិនជា X មិនទាន់បានប្រគល់ដី ហើយ Y បានទៅកាន់កាប់ដីនោះតាមទំនើងចិត្តរបស់ខ្លួន តុលាការមិនអាចទទួលស្គាល់នូវសិទ្ធិកាន់កាប់ដីរបស់ Y បានទេ។

ដើម្បីឱ្យអាចទទួលស្គាល់នូវសិទ្ធិកាន់កាប់របស់ Y បាន ចាំបាច់ត្រូវតែមានការប្រគល់ដីនោះ ពី X ទៅ Y ដោយផ្អែកលើភតិសន្យា។

## ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ

37

ការទាមទារ (សិទ្ធិ)

ការអះអាង (អង្គហេតុ)




បញ្ជាក់ភស្តុតាង (ភស្តុតាង)

តើនៅថ្ងៃទី15 ខែមីនា ឆ្នាំ2014 Y បានបង្កើតភតិសន្យាជួលដី ជាមួយនឹង X ហើយ X បានប្រគល់ដីនោះដោយផ្អែកលើភតិសន្យានោះ ទៅឱ្យ Y ដែរឬទេ គឺជាចំណុចវិវាទ។

Y ជាអ្នកមានបន្ទុកក្នុងការបញ្ជាក់ភស្តុតាងអំពីអត្ថិភាពនៃភតិសន្យា។

38

## ប្លុកដ្យ៉ាប្រ្កាម



អង្គហេតុដែលជាមូលហេតុនៃការទាមទារ



| | | |
|---|---|---|
| ① | X<br>សព្វថ្ងៃ គឺជាម្ចាស់កម្មសិទ្ធិដី | ○ |
| ② | Y<br>សព្វថ្ងៃ គឺជាអ្នកកាន់កាប់ដី | ○ |

ការតវ៉ាអំពីសិទ្ធិកាន់កាប់

| | | |
|---|---|---|
| ③ | X・Y<br>ថ្ងៃទី15មីនា2014<br>បានបង្កើតភតិសន្យាជួលដី ដោយគិតថ្លៃឈ្នួល 200ដុល្លារក្នុងមួយខែ អំឡុងពេលគឺ ពីថ្ងៃទី15 មីនា 2014 ដល់ថ្ងៃទី14 មីនា 2024។ | × |
| ④ | X→Y<br>ថ្ងៃទី15មីនា2014<br>ការប្រគល់ដី ដោយផ្អែកលើ ③ | × |

39

## ប្រភេទទី②　ការតវ៉ាអំពីការបាត់បង់កម្មសិទ្ធិ


40
X
Y
នៅថ្ងៃទី15 ខែមីនា ឆ្នាំ2014 ខ្ញុំបានទិញដីពី X ក្នុងតម្លៃ 20000ដុល្លារ។
ខ្ញុំនិង X បានបង្កើតកិច្ចសន្យាលក់ទិញ ដោយមានការទទួលស្គាល់ពីប្រធានភូមិ ហើយបានធ្វើនីតិវិធីចុះចញ្ជីផ្ទេរកម្មសិទ្ធិរួចរាល់ហើយ។
ដូច្នេះ បច្ចុប្បន្ននេះ ខ្ញុំជាម្ចាស់កម្មសិទ្ធិ។
(បច្ចុប្បន្ននេះគឺ ថ្ងៃទី18 មិថុនា 2014)


41
X
Y
ខ្ញុំបាននិយាយគ្នានឹង Y ពាក់ព័ន្ធនឹងការលក់ទិញដីពិតមែន ក៏ប៉ុន្តែមិនត្រូវរ៉ូវគ្នាអំពីតម្លៃ ដូច្នេះ មិនបានបង្កើតកិច្ចសន្យាលក់ទិញនៅឡើយទេ។
ហេតុនេះហើយ រវាងខ្ញុំ និង Y គ្មានកិច្ចសន្យាលក់ទិញទេ ហើយសព្វថ្ងៃនេះ ខ្ញុំនៅតែជាម្ចាស់កម្មសិទ្ធិលើដីនោះដដែល។
ប្រហែលជា Y បានធ្វើលិខិតនៃកិច្ចសន្យាក្លែងក្លាយ ហើយបានទៅសុំការបញ្ជាក់ពីមេភូមិ ព្រមទាំងទៅធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិតាមទំនើងចិត្តគាត់។




43

កម្មសិទ្ធិករនៅថ្ងៃនេះ បើសិនជាមិនធ្វើអំពើពិសេសអ្វីមួយទេ ថ្ងៃស្អែកក៏នៅតែជាកម្មសិទ្ធិករដែរ។



44

កម្មសិទ្ធិករនៅឆ្នាំនេះ បើសិនជាមិនធ្វើអំពើពិសេសអ្វីមួយទេ ឆ្នាំក្រោយក៏នៅតែជាកម្មសិទ្ធិករដដែរ។




45

ដូច្នេះ នេះគឺជាការវាយតម្លៃតាមផ្លូវច្បាប់ថា អ្នកដែលមានកម្មសិទ្ធិនៅចំណុចពេលណាមួយនៅអតីតកាល នៅតែជាអ្នកមានកម្មសិទ្ធិដដែលពេលបច្ចុប្បន្ននេះ បើសិនជាពុំមានហេតុការណ៍អ្វីមួយដែលធ្វើឱ្យអ្នកនោះបាត់បង់កម្មសិទ្ធិក្រោយពេលនោះទេ។




ការទាមទារ
(សិទ្ធិ)
ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
46
ការអះអាង
(អង្គហេតុ)
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
①ដើមចោទមានកម្មសិទ្ធិលើដីនៅថ្ងៃទី15 មីនា
②ចុងចម្លើយកាន់កាប់ដី
សារភាព
សារភាព
បើគិតអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺគ្រប់គ្រាន់ហើយ
ថ្ងៃទី15មីនា2014
មិនចាំបាច់អះអាងនិងបញ្ជាក់ភស្តុតាងទេ
កម្មសិទ្ធិ
កម្មសិទ្ធិ
ទទួលស្គាល់នូវកម្មសិទ្ធិរបស់ X នៅពេលនេះ
Y
Y


ការទាមទារ
(សិទ្ធិ)
ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
47
ការអះអាង
(អង្គហេតុ)
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
①ដើមចោទមានកម្មសិទ្ធិលើដីនៅថ្ងៃទី15 មីនា
②ចុងចម្លើយកាន់កាប់ដី
សារភាព
សារភាព
ថ្ងៃទី15មីនា2014
ការអះអាងរបស់ Y
កម្មសិទ្ធិ
បាត់បង់កម្មសិទ្ធិ
តើ X ឬ Y ត្រូវបញ្ជាក់ភស្តុតាង ?
កិច្ចសន្យាលក់ទិញ
ទទួលស្គាល់នូវកម្មសិទ្ធិរបស់ X នៅពេលនេះ
Y
Y




ដូចដែលបានពន្យល់ខាងលើនេះហើយ  អ្នកដែលមានកម្មសិទ្ធិនៅចំណុចពេលណាមួយនៅអតីតកាល នៅតែជាអ្នកមានកម្មសិទ្ធិដដែលពេលបច្ចុប្បន្ននេះ បើសិនជាពុំមានហេតុការណ៍អ្វីពិសេសទេក្រោយពេលនោះ។

ម្យ៉ាងទៀត ដើមចោទ X មានការពិបាកនឹងបញ្ជាក់ភស្តុតាងថា គាត់មិនបានបាត់បង់កម្មសិទ្ធិ។ នេះគឺជាការបញ្ជាក់ភស្តុតាងថា អង្គហេតុអ្វីមួយពុំមានអត្ថិភាព ហើយគឺជាការបញ្ជាក់អំពីព្រាយបីសាច។ ផ្ទុយទៅវិញ ចុងចម្លើយ Y មានការងាយស្រួលនឹងបញ្ជាក់ភស្តុតាងថា ដើមចោទ X បានបាត់បង់កម្មសិទ្ធិ ដោយសារតែគាត់មានការងាយស្រួលរកភស្តុតាង។

ដូច្នេះ ដើម្បីឱ្យមានសមធម៌  ចុងចម្លើយ Y ត្រូវតែធ្វើការអះអាងនិងបញ្ជាក់ភស្តុតាងអំពីការបាត់បង់កម្មសិទ្ធិរបស់ដើមចោទ X ។



## ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ

50




【ក្រមរដ្ឋប្បវេណី មាត្រា516 វាក្យខ័ណ្ឌទី1】
កិច្ចសន្យាលក់ទិញអាចត្រូវបានបង្កើតឡើង ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ ។

【ក្រមរដ្ឋប្បវេណី មាត្រា336】
១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្ទីការត្រូវគ្នា ។
២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

【ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា9 ចំណុច ក. វាក្យខ័ណ្ឌទី២】
ប៉ុន្តែ ចំពោះលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្ទីការ) និង មាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ក៏ជាលិខិតយថាភូតដែរ ។

## ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ

51




【ក្រមរដ្ឋប្បវេណី មាត្រា133】
ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ត្រូវមានអានុភាព តាមការព្រមព្រៀងរវាងភាគី ។

【ក្រមរដ្ឋប្បវេណី មាត្រា135】
ទោះបីមានបញ្ញត្តិនៃមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សដោយការព្រមព្រៀង) និង មាត្រា ១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) នៃក្រមនេះក៏ដោយ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង មិនមានអានុភាព បើមិនបានចុះបញ្ជី ដោយយោងតាមបញ្ញត្តិនៃច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត ស្តីពីការចុះបញ្ជី ។




⑤ស្តីពីអត្ថិភាព ឬនត្ថិភាពនៃការចុះបញ្ជីផ្ទេរកម្មសិទ្ធិ តើការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ដើមចោទ X ជាការសារភាព ឬក៏ជាការមិនទទួលស្គាល់ ?

បើសិនជាមើលតាមទម្រង់ គឺមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ហើយដើមចោទ X ក៏មិនមានវិវាទចំពោះចំណុចនេះដែរ។

ក៏ប៉ុន្តែ ដើមចោទ X បានអះអាងថា ចុងចម្លើយ Y បានចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយទំនើងចិត្តរបស់ខ្លួន។

ដូច្នេះ អានុភាពនៃការចុះបញ្ជីដោយមិនផ្អែកលើឆន្ទៈរបស់ភាគី គឺជាបញ្ហា។

ស្តីពីចំណុចនេះ ពុំមានចែងក្នុងបញ្ញត្តិច្បាប់ទេ ដូច្នេះ ត្រូវធ្វើការបកស្រាយ។




នៅក្នុងប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី ប្រការ ១០ កថាខ័ណ្ឌទី១ មានចែងថា "ពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវធ្វើឡើងរួមគ្នា ដោយបុគ្គលមានសិទ្ធិចុះបញ្ជី និងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី" ។

ប្រការនេះត្រូវបានចែងដោយផ្អែកលើគំនិតតម្រូវឱ្យដាក់ពាក្យសុំចុះបញ្ជីដោយផ្អែកលើឆន្ទៈរបស់ភាគីទាំងសងខាង។

ដូច្នេះ អាចបកស្រាយថា ការដាក់ពាក្យសុំចុះបញ្ជីដោយមិនផ្អែកលើឆន្ទៈរបស់ភាគីទេ ពុំមានសុពលភាពទេ។

បើសិនជាមើលមករឿងក្តីនេះវិញ ដើមចោទ X បានអះអាងថា "គ្មានការចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើឆន្ទៈរបស់ភាគីទេ" ដូច្នេះ មិនទទួលស្គាល់នូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិ⑤ ទេ។


ការទាមទារ
(សិទ្ធិ)
ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
54
ការអះអាង
(អង្គហេតុ)
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
អង្គហេតុតវ៉ា
ការបាត់បង់កម្មសិទ្ធិរបស់ដើមចោទ
①ដើមចោទមានកម្មសិទ្ធិលើដីនៅថ្ងៃទី15 មីនា
②ចុងចម្លើយកាន់កាប់ដី
③កិច្ចសន្យាលក់ទិញ
④ធ្វើឯកសារ
⑤ចុះបញ្ជីផ្ទេរ
សារភាព
សារភាព
មិនទទួលស្គាល់
មិនទទួលស្គាល់
មិនទទួលស្គាល់
ចំណុចវិវាទ
បញ្ជាក់ភស្តុតាង
(ភស្តុតាង)
ចណុចវិវាទគឺ តើនៅថ្ងៃទី15 ខែមីនា ឆ្នាំ2014 X និង Y បានបង្កើតកិច្ចសន្យាលក់ទិញដី ហើយបានបង្កើតលិខិតនៃកិច្ចសន្យា យកទៅចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយមានសុពលភាព ឬទេ។
ស្តីពីអង្គហេតុទាំងនេះ Y ជាអ្នកមានបន្ទុកក្នុងការបញ្ជាក់ភស្តុតាង។


ប្រកដ្យ៉ាប្រោម
55
ការតវ៉ាអំពីការបាត់បង់កម្មសិទ្ធិ
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
① X មានកម្មសិទ្ធិលើដីនៅថ្ងៃទី15 មីនា2014 ○
② Y បច្ចុប្បន្ន មានកម្មសិទ្ធិលើដី ○
③ X・Y ថ្ងៃទី15មីនា2014 កិច្ចសន្យាលក់ទិញដី តម្លៃ 20000ដុល្លារ ×
④ ធ្វើលិខិតយថាភូតពាក់ព័ន្ធនឹង ③ ហើយបានធ្វើឯកសារជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើនីតិវិធីចុះបញ្ជីដោយមន្ត្រីដែលមានសិទ្ធិ ×
⑤ X→Y ចុះបញ្ជីផ្ទេរកម្មសិទ្ធិពាក់ព័ន្ធនឹង ③ ×

56




សំខាន់គឺ មិនមែនបញ្ហាថា "តើ Y បានធ្វើលទ្ធកម្មកម្មសិទ្ធ ឬទេ" នោះទេ។ គឺបញ្ហាថា "តើ X បានបាត់បង់កម្មសិទ្ធិឬទេ"។

57




សំខាន់គឺ មិនមែនបញ្ហាថា "តើ Y បានធ្វើលទ្ធកម្មកម្មសិទ្ធ ឬទេ" នោះទេ។ គឺបញ្ហាថា "តើ X បានបាត់បង់កម្មសិទ្ធិឬទេ"។




ស្តីពីករណីដែល Z បានទិញដីពី X ហើយ Y បានជួលដី នោះពី Z ក៏ទម្រង់នៃការរៀបចំចំណុចវិវាទមានដូចគ្នាដែរ។


58
ការទាមទារ (សិទ្ធិ)
ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
ការអះអាង (អង្គហេតុ)
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
អង្គហេតុតវ៉ាការបាត់បង់កម្មសិទ្ធិរបស់ដើមចោទ
①ដើមចោទមានកម្មសិទ្ធិលើដីនៅថ្ងៃទី15 មីនា
②ចុងចម្លើយកាន់កាប់ដី
③កិច្ចសន្យាលក់ទិញ
④ធ្វើឯកសារ
⑤ចុះបញ្ជីផ្ទេរ
ការអះអាងរបស់ Y
កម្មសិទ្ធិ
បាត់បង់កម្មសិទ្ធិ
កិច្ចសន្យាលក់ទិញ
Z
ជួល
Y


59
ប្លុកដ្យ៉ាក្រាម
ការតវ៉ាអំពីការបាត់បង់កម្មសិទ្ធិ
Y
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
① X នៅថ្ងៃទី15មីនា2014 មានកម្មសិទ្ធិលើដី ○
② Y បច្ចុប្បន្ន កាន់កាប់ដី ○
③ X・Z ថ្ងៃទី15មីនា2014 កិច្ចសន្យាលក់ទិញដី តម្លៃ20000ដុល្លារ ×
④ ធ្វើលិខិតយថាភូតពាក់ព័ន្ធនឹង ③ ហើយបានធ្វើឯកសារជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើនីតិវិធីចុះបញ្ជីដោយមន្ត្រីដែលមានសិទ្ធិ ×
⑤ ចុះបញ្ជីផ្ទេរកម្មសិទ្ធិពាក់ព័ន្ធនឹង③ ×

60

ប្រភេទទី③ ការមិនទទួលស្គាល់នូវលទ្ធកម្មកម្មសិទ្ធិ

61




ដើមចោទបានអះអាងដូចជាខ្លួនមានកម្មសិទ្ធិលើដី ក៏ប៉ុន្តែ
មិនមែនទេ គឺ Z ជាម្ចាស់កម្មសិទ្ធិលើដីនោះទេ។
ខ្ញុំបានជួលដីនោះពី Z មកប្រើ។


62
X
Y
នៅថ្ងៃទី15 មីនា 2014 ខ្ញុំបានទិញដីនោះពី Z ក្នុងតម្លៃ 20000ដុល្លារ។
ខ្ញុំបានបង្កើតកិច្ចសន្យាលក់ទិញ ហើយមានការទទួលស្គាល់ពីប្រធានភូមិ ហើយក៏បានធ្វើនីតិវិធីចុះបញ្ជីរួចហើយ។
ហេតុនេះហើយ បច្ចុប្បន្ន ខ្ញុំជាម្ចាស់កម្មសិទ្ធិលើដីនោះ។


63
X
Y
Z និង X បានជជែកគ្នាអំពីការលក់ទិញដីនោះ ក៏ប៉ុន្តែគេមិនត្រូវរ៉ូវគ្នាអំពីតម្លៃទេ ដូច្នេះ មិនទាន់បានបង្កើតកិច្ចសន្យាលក់ទិញទេ។
រឿងនេះ ខ្ញុំបានឮពី Z ។ ហេតុនេះហើយ រវាង Z និង X ពុំមានកិច្ចសន្យាលក់ទិញទេ ហើយសព្វថ្ងៃនេះ Z មានកម្មសិទ្ធិលើដីនោះ។
ប្រហែលជា X បានក្លែងបន្លំលិខិតនៃកិច្ចសន្យានោះ ហើយទៅសុំឱ្យប្រធានភូមិទទួលស្គាល់ បន្ទាប់មក យកទៅធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិហើយ។


ការទាមទារ (សិទ្ធិ)
ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
64
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
ការអះអាង (អង្គហេតុ)
ដើមចោទមានកម្មសិទ្ធិលើដី
មិនទទួលស្គាល់?
ចុងចម្លើយកាន់កាប់ដី
សារភាព
ការអះអាងរបស់ Y
កម្មសិទ្ធិ
Z


ការទាមទារ (សិទ្ធិ)
ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
65
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
ការអះអាង (អង្គហេតុ)
ដើមចោទមានកម្មសិទ្ធិលើដី
មិនទទួលស្គាល់?
ចុងចម្លើយកាន់កាប់ដី
សារភាព
ការអះអាងរបស់ X
ថ្ងៃទី15មីនា2014
កម្មសិទ្ធិ
Z
កិច្ចសន្យាលក់ទិញ
ទទួលស្គាល់នូវកម្មសិទ្ធិរបស់ Z នៅពេលនេះ
Y
កម្មសិទ្ធិ


ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
66
ការទាមទារ
(សិទ្ធិ)
ការអះអាង
(អង្គហេតុ)
អង្គហេតុដែលជាមូល
ហេតុនៃការទាមទារ
ថ្ងៃទី15 មីនា
Z មានកម្មសិទ្ធិលើដី
សារភាព
តើដើមចោទ X ត្រូវធ្វើការអះអាងនូវ
អង្គហេតុផ្សេងទៀតយ៉ាងណាខ្លះ ?
ចុងចម្លើយកាន់កាប់ដី
សារភាព
ការអះអាងរបស់ X
ថ្ងៃទី15មីនា2014
កម្មសិទ្ធិ
Z
ទទួលស្គាល់នូវកម្ម
សិទ្ធិរបស់ Z នៅ
ពេលនេះ
Y
កិច្ចសន្យាលក់ទិញ
កម្មសិទ្ធិ


ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
67
ការទាមទារ
(សិទ្ធិ)
ការអះអាង
(អង្គហេតុ)
អង្គហេតុដែលជាមូល
ហេតុនៃការទាមទារ
ថ្ងៃទី15 មីនា
Z មានកម្មសិទ្ធិលើដី
ថ្ងៃទី15 មីនា
Z→X លក់ទិញដី
ធ្វើឯកសារ
ចុះបញ្ជីផ្ទេរ
ចុងចម្លើយកាន់កាប់ដី
សារភាព
សារភាព
អង្គហេតុដែលជាមូលហេតុ
នៃលទ្ធកម្មកម្មសិទ្ធិ
ដី
កម្មសិទ្ធិ
Z


ការទាមទារ (សិទ្ធិ)
ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
68
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
ការអះអាង (អង្គហេតុ)
ថ្ងៃទី15 មីនា Z មានកម្មសិទ្ធិលើដី
ថ្ងៃទី15 មីនា Z→X លក់ទិញដី
ធ្វើឯកសារ
ចុះបញ្ជីផ្ទេរ
ចុងចម្លើយកាន់កាប់ដី
សារភាព
មិនទទួលស្គាល់
មិនទទួលស្គាល់
មិនទទួលស្គាល់
សារភាព
ដី
កម្មសិទ្ធិ
Z


ការទាមទារ (សិទ្ធិ)
ការទាមទារឱ្យរើហើយប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ
69
អង្គហេតុដែលជាមូលហេតុនៃការទាមទារ
ការអះអាង (អង្គហេតុ)
ថ្ងៃទី15 មីនា Z មានកម្មសិទ្ធិលើដី
ថ្ងៃទី15 មីនា Z→X លក់ទិញដី
ធ្វើឯកសារ
ចុះបញ្ជីផ្ទេរ
ចុងចម្លើយកាន់កាប់ដី
សារភាព
មិនទទួលស្គាល់
មិនទទួលស្គាល់
មិនទទួលស្គាល់
សារភាព
ចំណុចវិវាទ
បញ្ជាក់ភស្តុតាង (ភស្តុតាង)
ចំណុចវិវាទគឺ តើនៅថ្ងៃទី15 មីនា 2014 X និង Z បានបង្កើតកិច្ចសន្យាលក់ទិញ ហើយធ្វើជាលិខិតនៃកិច្ចសន្យា ទៅចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយមានសុពលភាពឬទេ ?
ស្តីពីអង្គហេតុទាំងនេះ X មានបន្ទុកក្នុងការបញ្ជាក់ភស្តុតាង។

70

ប្តូកដ្យាំប្រក្លាម

អង្គហេតុដែលជាមូលហេតុនៃការទាមទារ



| | | |
|---|---|---|
| ① | Z<br>នៅថ្ងៃទី15មីនា2014<br>មានកម្មសិទ្ធិលើដី | ○ |
| ② | Z・X<br>ថ្ងៃទី15មីនា2014<br>កិច្ចសន្យាលក់ទិញដី<br>20000ដុល្លារ | × |
| ③ | ធ្វើលិខិតយថាភូតពាក់ព័ន្ធនឹង②<br>ហើយបានផ្ញើឯកសារជាលាយលក្ខណ៍អក្សរ<br>ដើម្បីធ្វើនីតិវិធីចុះបញ្ជីដោយមន្ត្រីដែលមាន<br>សិទ្ធិ | × |
| ④ | ចុះបញ្ជីផ្ទេរកម្មសិទ្ធិពាក់ព័ន្ធនឹង② | × |
| ⑤ | Y<br>សព្វថ្ងៃនេះ កាន់កាប់ដី | ○ |

71




ដូចដែលបានរៀបរាប់ខាងលើនេះ នៅក្នុងដំណាក់កាលនៃការជំនុំជម្រះ ការអះអាងរបស់ភាគីក៏មានភាពច្បាស់លាស់ ហើយតុលាការក៏បានរៀបចំចំណុចវិវាទបានរួចរាល់។

72




នៅក្នុងដំណាក់កាលនៃការដាក់ពាក្យបណ្ដឹង បើសិនជាមិនអាចព្យាករណ៍ថា ចុងចម្លើយនឹងតតាំងយ៉ាងដូចម្ដេចទេ ដើមចោទគ្រាន់តែអះអាងថា ①ដើមចោទមានកម្មសិទ្ធិលើដី, ②ចុងចម្លើយកាន់កាប់ដី ជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ ជាការគ្រប់គ្រាន់ហើយ។

| | |
|---|---|
| ① | ដើមចោទមានកម្មសិទ្ធិលើដី |
| ② | ចុងចម្លើយកាន់កាប់ដី |

73




នៅក្នុងដំណាក់កាលនៃការដាក់ពាក្យបណ្ដឹង បើសិនជាអាចព្យាករណ៍ថា ចុងចម្លើយនឹងតតាំងយ៉ាងដូចម្ដេច ដើមចោទអាចអះអាងអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារទៅតាមការតតាំងរបស់ចុងចម្លើយក៏បានដែរ។

ឧទាហរណ៍ បើសិនជាបានព្យាករណ៍ថា ចុងចម្លើយនឹងអះអាងអំពីការតវ៉ាស្ដីពីការបាត់បង់កម្មសិទ្ធិ ដូច្នេះ ចុងចម្លើយច្បាស់ជានឹងសារភាពអំពីកម្មសិទ្ធិរបស់ដើមចោទនៅពេលណាមួយនៃអតីតកាល ហេតុនេះដើមចោទអាចអះអាងនូវអង្គហេតុដែលជាមូលហេតុនៃការទាមទារដូចតទៅបាន ៖

| | |
|---|---|
| ① | ដើមចោទ<br>នៅថ្ងៃទី● ខែ● ឆ្នាំ● មានកម្មសិទ្ធិលើដី |
| ② | ចុងចម្លើយកាន់កាប់ដី |

សូមអរគុណចំពោះការយកចិត្តទុកដាក់
របស់លោកអ្នក !

